## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹងការផ្តល់សេវាសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាលឯកជន

ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា៖ ដើម្បីបន្តពង្រឹងការងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាលឯកជនឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសសុខាភិបាល និងត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈសុខាភិបាលនីមួយៗ និងច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យសុខាភិបាលឱ្យបានហ្មត់ចត់ ក្រសួងតែងតែធ្វើការណែនាំ ក្រើនរំលឹក និងបានចេញសេចក្តីណែនាំជាបន្តបន្ទាប់ជូនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី-ខេត្ត ព្រមទាំងម្ចាស់មូលដ្ឋានសុខាភិបាលឯកជនទាំងអស់ មានដូចជា ក្នុងពេលថ្មីៗនេះ មានចេញផ្សាយនូវសេចក្តីណែនាំស្តីពីការពង្រឹងសេវាសង្គ្រោះបន្ទាន់ក្នុងមន្ទីរពេទ្យ សេវារថយន្តសង្គ្រោះដើម្បីជួយសង្គ្រោះបន្ទាន់ ឬដឹកអ្នករងរបួសធ្ងន់ធ្ងរ ព្រមទាំងការផ្សព្វផ្សាយពីច្បាប់ និងបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន ជាពិសេសច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល និងច្បាប់ស្តីពីការរំលូតកូន ជាដើម។ លើសពីនេះ គណៈវិជ្ជាជីវៈវិស័យសុខាភិបាល មានដូចជា គណៈគ្រូពេទ្យ គណៈឆ្មប គណៈឱសថការី គណៈទន្តពេទ្យ និងគណៈគិលានុបដ្ឋាក បាននិងកំពុងធ្វើកិច្ចការពង្រឹងការអនុវត្ត និងការប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលទៅតាមជំនាញរៀងៗខ្លួន។

ដោយសង្កេតឃើញថា ការគ្រប់គ្រងនិងការផ្តល់សេវាសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាលឯកជនមួយចំនួនតូចមានលេចចេញជាបាតុភាពជាបន្តបន្ទាប់ ក្រសួងសុខាភិបាលសូមធ្វើការណែនាំក្រើនរំលឹកដល់អ្នកគ្រប់គ្រង និងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលឯកជនទាំងអស់សារជាថ្មីម្តងទៀតថា មូលដ្ឋានសុខាភិបាលឯកជនទាំងអស់ មានដូចជា បន្ទប់ពិគ្រោះថែទាំជំងឺ មន្ទីរព្យាបាលជំងឺ ជាពិសេស មន្ទីរពហុព្យាបាល និងមន្ទីរសម្ភព-រោគស្ត្រី។ល។ ចាំបាច់ត្រូវខិតខំគ្រប់គ្រងដំណើរការរបស់ខ្លួនឱ្យបានល្អប្រសើរត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសសុខាភិបាល ត្រូវតែគោរពអនុវត្តតាមតួនាទី ភារកិច្ច និងក្រមសីលធម៌វិជ្ជាជីវៈរៀងៗខ្លួន ដោយអនុលោមតាមច្បាប់ជាធរមាន។ អ្នកដែលប្រព្រឹត្តខុសឆ្គងពីវិជ្ជាជីវៈ ឬមានការធ្វេសប្រហែសលើការងារគ្រប់គ្រងមូលដ្ឋានសុខាភិបាលឯកជនរបស់ខ្លួន ឬធ្វើឱ្យមានកំហុសបច្ចេកទេសធ្ងន់ធ្ងរណាមួយបន្ថែមលើការដាក់វិន័យ នៃគណៈវិជ្ជាជីវៈនីមួយៗ និងត្រូវប្រឈមទៅនឹងច្បាប់ទៅតាមសណ្ឋានទម្ងន់ទោសដែលមានចែងនៅក្នុងច្បាប់ទាំងនោះ។ ដើម្បីជាការក្រើនរំលឹកនូវច្បាប់សំខាន់ៗ សម្រាប់ការចូលរួមអនុវត្តការគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលឱ្យបានល្អប្រសើរ ក្រសួងសូមភ្ជាប់ជូនមកជាមួយនូវ៖

១. ច្បាប់ស្តីពីការរំលូតកូន ចំនួន ៨ទំព័រ
២. ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ចំនួន ១១ទំព័រ។

ក្រសួងសូមណែនាំ និងជំរុញបន្ថែមទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី-ខេត្តទាំងអស់ បន្តយកចិត្តទុកដាក់ត្រួតពិនិត្យការងារផ្តល់សេវាសុខាភិបាលឯកជន ក៏ដូចជាមានការពង្រឹងបន្ថែមទៀតនូវការចេញអាជ្ញាបណ្ណ ឬច្បាប់អនុញ្ញាតនានាពាក់ព័ន្ធទៅនឹងសេវាសុខាភិបាលឯកជន នៅតាមដែនសមត្ថកិច្ចរៀងៗខ្លួនឱ្យបានកាន់តែល្អប្រសើរឡើង ដើម្បីសុខភាព និងសុខុមាលភាពប្រជាជនយើង។



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

សម្រាប់បងប្អូនប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ សូមអញ្ជើញទៅពិនិត្យ និងពិគ្រោះជំងឺនៅតាមមូលដ្ឋានសុខាភិបាលដែលមានជំនាញ និងបច្ចេកទេសត្រឹមត្រូវ ដើម្បីចៀសវាងហេតុការណ៍ដែលអាចកើតមានឡើងជាយថាហេតុ។

ក្រសួងសុខាភិបាលសង្ឃឹមយ៉ាងមុតមាំថា មន្ត្រីសុខាភិបាលទាំងអស់ ត្រូវអនុវត្តឲ្យបានយ៉ាងត្រឹមត្រូវនូវក្រមសីលធម៌វិជ្ជាជីវៈ និងច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ដើម្បីបម្រើសេវាសុខាភិបាលជូនប្រជាជនឲ្យកាន់តែល្អប្រសើរថែមទៀត។ ជាមួយគ្នានេះ សូមបងប្អូនប្រជាពលរដ្ឋ ចូលរួមសហការជាមួយមន្ត្រីសុខាភិបាល និងគោរពឲ្យបានខ្ជាប់ខ្ជួននូវសិទ្ធិ និងកាតព្វកិច្ចចំពោះអ្នកផ្តល់សេវា និងអ្នកទទួលសេវា។

ថ្ងៃសៅរ៍ ១០កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម_ប៊ុនហេង**



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# ច្បាប់

ស្តីពី

# ការរំលូតកូន

នស/រកម/១១៩៧/០៦

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

* * * * * * * * *


រដ្ឋសភា
ចូល
លេខ ១៩៥៤
ថ្ងៃទី ២៤.១០.៩៧ ម៉ោង ១៧:10
បញ្ជូនទៅ ...


- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស-៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត-០៨៩៧-១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពី រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីការរំលូតកូន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ពីបែបបទនិងល័ក្ខខ័ណ្ឌនៃការរំលូតកូន ។

**មាត្រា ២.-**

ការរំលូតកូនគឺជាការបញ្ឈប់គភ៌តាមវិធីវេជ្ជសាស្ត្រឬតាមវិធីណាមួយ ។

**មាត្រា ៣.-**

ស្ត្រីមានគភ៌ទាំងឡាយអាចសុំឱ្យគ្រូពេទ្យធ្វើការរំលូតកូនបាន ក្រោយពីបានបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា ៤.-**

ក្នុងករណីណាក៏ដោយ ការរំលូតកូនត្រូវតែមានសំណូមពរនិងបានទទួលការយល់ព្រមពីស្ត្រីដែលមានគភ៌ ។

**មាត្រា ៥.-**

មានតែវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យមដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ទើបអាចធ្វើការរំលូតកូនបាន ។

# ជំពូកទី ២

## បែបបទនិងល័ក្ខខ័ណ្ឌ

**មាត្រា ៦.-**

ការរំលូតកូនប្រព្រឹត្តទៅបានតែនៅក្នុងមន្ទីរពេទ្យ មណ្ឌលសុខភាព គ្លីនិក មន្ទីរសម្ភពសាធារណៈឬឯកជនដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ។ រាល់សេវាដែលក្រសួងសុខាភិបាលបានអនុញ្ញាតឱ្យជាកន្លែងធ្វើការរំលូតកូនត្រូវមាន :

-លទ្ធភាពបច្ចេកទេសព្យាបាលបន្ទាន់នូវរាល់ផលវិបាកនៃការរំលូតកូន

-មធ្យោបាយបញ្ជូនទៅមន្ទីរពេទ្យ ប្រសិនបើមានការចាំបាច់

**មាត្រា ៧.-**

វេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬឆ្មបមធ្យមដែលមានភារកិច្ចធ្វើការរំលូតកូន ត្រូវពន្យល់ណែនាំដល់ស្ត្រីដែលមានគភ៌ដែលមកសុំធ្វើការរំលូតកូន ពីគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុបណ្ដាលមកពីការរំលូតកូននេះនិងពីផលប្រយោជន៍នៃកិច្ចពន្យារកំណើត ។

ប្រសិនបើស្ត្រីដែលមានគភ៌នោះ នៅតែទទូចសុំធ្វើការរំលូតកូន វេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬឆ្មបមធ្យមអាចធ្វើការរំលូតបាន តែត្រូវស្ថិតក្នុងល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ។

**មាត្រា ៨.-**

ការរំលូតកូនអាចធ្វើទៅបាន ចំពោះតែគភ៌ណាដែលមានអាយុតិចជាង ១២សប្ដាហ៍។ លើសពី ១២សប្ដាហ៍នៃអាយុគភ៌ ការរំលូតកូនអាចទទួលការអនុញ្ញាតបាន លុះតែក្នុងពេលធ្វើរោគវិនិច្ឆ័យឃើញថា :

-គភ៌នោះមានភាវនីយភាពមិនលូតលាស់ដូចប្រក្រតីឬបង្កគ្រោះថ្នាក់ដល់ជីវិតម្ដាយ

-កូនដែលនឹងកើតមកអាចមានជម្ងឺធ្ងន់ធ្ងរព្យាបាលពុំជា

-ក្នុងករណីដែលត្រូវគេរំលោភបណ្ដាលឱ្យមានគភ៌ ការរំលូតកូនអាចប្រព្រឹត្តទៅបាន ដោយមិនគិតពីល័ក្ខខ័ណ្ឌដូចមានចែងខាងលើ តែត្រូវមានការស្នើសុំពីសាមីខ្លួន បើស្ត្រីនោះមាន

អាយុ ១៨ឆ្នាំ ឡើងទៅ ឬការស្នើសុំដោយទទួលពីឪពុកម្តាយឬអាណាព្យាបាលនិងសាមីខ្លួន បើស្ត្រីដែលមានគភ៌មានអាយុតិចជាង ១៨ឆ្នាំ ។

ការសំរេចនៃបញ្ហានេះ ត្រូវមានការឯកភាពពីក្រុមគ្រូពេទ្យ ២ ឬ ៣រូប រួមទាំងសាមីខ្លួនផង។ល័ក្ខខ័ណ្ឌបច្ចេកទេសសម្រាប់ការអនុវត្តនៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៩.-**

រាល់ឯកសារដែលទាក់ទងទៅនឹងការរំលូតកូន ត្រូវរក្សាទុកជាការសម្ងាត់ ហើយអាចផ្តល់ទៅសាមីខ្លួន ឬតុលាការប្រសិនបើមានការស្នើសុំជាលាយល័ក្ខអក្សរ ។

**មាត្រា ១០.-**

សេវាដែលក្រសួងសុខាភិបាលបានអនុញ្ញាតឱ្យជាកន្លែងធ្វើការរំលូតកូនដូចមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវរៀបចំឯកសារច្បាស់លាស់ស្តីពីករណីរំលូតកូននីមួយៗហើយត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រសួងសុខាភិបាលដោយឡែងទាត់នូវចំនួនរំលូតកូននិងមធ្យោបាយរំលូត។

## ជំពូកទី ៣

## សមត្ថកិច្ចត្រួតពិនិត្យ

**មាត្រា ១១.-**

ការត្រួតពិនិត្យការរំលូតកូនតាមការកំណត់នៃច្បាប់នេះ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

# ជំពូកទី ៤

## ទោសប្បញ្ញត្តិ

**មាត្រា ១២.–**

ជនទាំងឡាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ ឬ ៦ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មនិងទោសទណ្ឌដូចខាងក្រោម :

បើជាវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬជាឆ្មបមធ្យមត្រូវព្រមាន ។ ក្នុងករណីមិនរាងចាលត្រូវបញ្ឈប់ពីមុខងារឬបិទគ្លីនិកឬមន្ទីរសម្ភពនោះដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដូចចែងខាងក្រោមនេះ ។

បើមិនមែនជាវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬជាឆ្មបមធ្យមត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ ។

-បើការរំលូតកូននោះបណ្តាលឱ្យស្ត្រីដែលមានគភ៌មានជម្ងឺរ៉ាំរ៉ៃឬពិការ ត្រូវផ្តន្ទាទោសពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

-បើការរំលូតកូនបណ្តាលឱ្យស្ត្រីដែលមានគភ៌មានគ្រោះថ្នាក់ដល់ស្លាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ។

**មាត្រា ១៣.–**

វេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬឆ្មបមធ្យមដែលបានទទួលការអនុញ្ញាតឱ្យធ្វើការរំលូតកូនហើយមិនគោរពល័ក្ខខ័ណ្ឌណាមួយដូចចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ត្រូវដកហូតយកលិខិតអនុញ្ញាតដែលចេញឱ្យដោយក្រសួងសុខាភិបាល ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

លើកលែងតែក្នុងករណីធ្ងន់ធ្ងរដែលស្ត្រីមានគភ៌ត្រូវសង្គ្រោះបន្ទាន់ វិធីវេជ្ជសាស្ត្រនឹងត្រូវបានធានាចំពោះមុខច្បាប់ ។

**មាត្រា ១៤.-**

ជនទាំងឡាយណា ដែលបង្ខិតបង្ខំឱ្យស្ត្រីដែលមានគភ៌ធ្វើការរំលូតកូន ឬធ្វើឱ្យរលូតកូនដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ។ បើការបង្ខិតបង្ខំឱ្យស្ត្រីដែលមានគភ៌ធ្វើការរំលូតកូន ឬធ្វើឱ្យរលូតកូនដោយចេតនានោះបណ្តាលឱ្យស្ត្រីដែលមានគភ៌មានជម្ងឺរ៉ាំរ៉ៃ ពិការ ឬបណ្តាលឱ្យស្លាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

**មាត្រា ១៥.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៩ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

-បើជាមន្ត្រីរាជការ ត្រូវទទួលទណ្ឌកម្មតាមមាត្រា ៤០ និង ៤១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

-បើមិនមែនជាមន្ត្រីរាជការ ត្រូវបិទគ្លីនិក ឬមន្ទីរសម្ភពឯកជនពី ១ខែ ទៅ ៣ខែ ឬពិន័យជាប្រាក់ពី ប្រាំលានរៀល ( ៥.០០០.០០០រៀល ) ដល់ ដប់លានរៀល (១០.០០០.០០០រៀល) ។

# ជំពូកទី ៥

# អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និង តាមព្រះរាជព្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១

ហត្ថលេខា

អ៊ឹង ហួត

នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ហត្ថលេខា

ឈា ថាំង

លេខ : ៤០ ចល

ដើម្បីចំលងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ១៩៩៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

# ព្រះរាជក្រម

នស/រកម/១១១៦/០១៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈ
# វិស័យសុខាភិបាល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារសុខភាព និងសុវត្ថិភាពរបស់ប្រជាជនតាមរយៈ ការផ្ដល់នូវយន្តការក្នុងការធានាថា អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់មានគុណវុឌ្ឍិ សមត្ថភាព និងសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈ សុខាភិបាល និងការប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ ៖

**អ្នកវិជ្ជាជីវៈសុខាភិបាល** សំដៅដល់គ្រូពេទ្យ ទន្តពេទ្យ ឆ្មប គិលានុបដ្ឋាក ឱសថការី អ្នកបច្ចេកទេសមន្ទីរពិសោធន៍សុខាភិបាល អ្នកព្យាបាលដោយចលនា ទន្តគិលានុបដ្ឋាក អ្នកបច្ចេកទេសវិទ្យុសាស្ត្រ និងអ្នកវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតដែលទទួលបានការចុះ បញ្ជិកាជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

**អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់អ្នកវិជ្ជាជីវៈសុខាភិបាលដែលទទួល បានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ។

**ការប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់ការអនុវត្តវិជ្ជាជីវៈដែលស្ថិតនៅក្នុងដែនកំណត់វិជ្ជាជីវៈសុខាភិបាលនៃមុខវិជ្ជាជីវៈសុខាភិបាលនីមួយៗ ។

**បញ្ជីគណៈវិជ្ជាជីវៈសុខាភិបាល** សំដៅដល់បញ្ជីគណៈគ្រូពេទ្យកម្ពុជា បញ្ជីគណៈទន្តពេទ្យកម្ពុជា បញ្ជីគណៈឱសថការីកម្ពុជា បញ្ជីគណៈឆ្មបកម្ពុជា បញ្ជីគណៈគិលានុបដ្ឋាកកម្ពុជា និងបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាលផ្សេងៗទៀត ដែលមានកំណត់ត្រានៃឈ្មោះ និងព័ត៌មានផ្សេងៗរបស់អ្នកវិជ្ជាជីវៈសុខាភិបាលនិងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល តាមបញ្ញត្តិនៃច្បាប់នេះ ហើយបញ្ជីនេះត្រូវគ្រប់គ្រងដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

**ការចុះបញ្ជិកា** សំដៅដល់ដំណើរការនៃការចុះបញ្ជីបុគ្គលម្នាក់ទៅជាអ្នកវិជ្ជាជីវៈសុខាភិបាល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង



ឈ/

អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល សំដៅដល់ការអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈសុខាភិបាល ដែលផ្តល់ដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ បន្ទាប់ពីមានការចុះបញ្ជិកា និងការបំពេញលក្ខខណ្ឌ ដើម្បីទទួលបានអាជ្ញាបណ្ណស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

**កំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល** សំដៅដល់រាល់កំហុសឆ្គងទាំងឡាយដែលខុសនឹង ក្រមសីលធម៌វិជ្ជាជីវៈ បទដ្ឋានវិជ្ជាជីវៈ និយាមវិជ្ជាជីវៈ និងដែនកំណត់វិជ្ជាជីវៈសុខាភិបាល ដោយអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ។

## ជំពូកទី ២
## សមត្ថកិច្ចគ្រប់គ្រង

### មាត្រា ៥.-

គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗមានសមត្ថកិច្ចក្នុងការចុះបញ្ជិកានិងផ្តល់អាជ្ញា បណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ព្រមទាំងគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ។

បទប្បញ្ញត្តិស្តីពីបទដ្ឋានវិជ្ជាជីវៈ និងនិយាមវិជ្ជាជីវៈ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

## ជំពូកទី ៣
## ការប្រកបវិជ្ជាជីវៈសុខាភិបាល

### មាត្រា ៦.-

បុគ្គលទាំងឡាយដែលមានបំណងប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវ ៖

-ចុះបញ្ជិកាក្នុងបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាល

-មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ។

### មាត្រា ៧.-

ក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវ ៖

-មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ដែលមានសុពលភាព

-គោរពក្រមសីលធម៌វិជ្ជាជីវៈ បទដ្ឋានវិជ្ជាជីវៈ និងនិយាមវិជ្ជាជីវៈ

-អនុវត្តការងារក្នុងដែនកំណត់វិជ្ជាជីវៈសុខាភិបាល ។

### មាត្រា ៨.-

បុគ្គលដែលអាចស្នើសុំចុះបញ្ជិកា ត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

-មានគុណវុឌ្ឍិក្នុងវិជ្ជាជីវៈរបស់ខ្លួន ដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាល

-មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

- មិនមានបញ្ហាសុខភាពខាងផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈរបស់ខ្លួន
- ការស្នើសុំចុះបញ្ជិកាត្រូវធ្វើនៅគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

បែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវផ្សេងៗទៀតក្នុងការចុះបញ្ជិកា ត្រូវកំណត់ដោយគណៈ-វិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

**មាត្រា ៩.-**

អ្នកវិជ្ជាជីវៈសុខាភិបាលដែលអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ត្រូវបំពេញលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

- បានចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ
- រក្សាបាននិយាមតម្រូវសម្រាប់សមត្ថភាពក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល
- បង្ហាញថាមានបច្ចុប្បន្នភាពសមត្ថភាព ឬបទពិសោធថ្មីៗដែលច្បាប់តម្រូវសម្រាប់ការប្រកបវិជ្ជាជីវៈ
- មិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋណាមួយ នៅក្នុងប្រទេសកម្ពុជា ឬនៅក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ
- មិនមានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈសុខាភិបាល
- ការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវធ្វើនៅគណៈវិជ្ជាជីវៈ សុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

បែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវផ្សេងៗទៀតក្នុងការផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ។

**មាត្រា ១០.-**

លក្ខខណ្ឌ និងនីតិវិធីក្នុងការបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវកំណត់ដោយ គណៈ-វិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ១១.-**

ជនបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈសុខាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវដាក់ពាក្យស្នើសុំចុះបញ្ជិកា និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល នៅគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធណាមួយស្របតាមមុខវិជ្ជាជីវៈរបស់ខ្លួន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ១២.-**

ដែនកំណត់វិជ្ជាជីវៈសុខាភិបាលនៃមុខវិជ្ជាជីវៈសុខាភិបាលនីមួយៗ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈ សុខាភិបាលដែលពាក់ព័ន្ធដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## ជំពូកទី ៤
## សម្បទាក្នុងការប្រកបវិជ្ជាជីវៈ

**មាត្រា ១៣.-**

អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលអាចត្រូវបានចាត់ទុកថាមិនមានសម្បទាក្នុងការប្រកបវិជ្ជាជីវៈ សុខាភិបាល ប្រសិនបើ ៖

- មិនបានបំពេញតាមលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ដែលកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ
- បានប្រព្រឹត្តកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ដែលនាំទៅដល់ការផ្អាកអាជ្ញាបណ្ណវិជ្ជាជីវៈ សុខាភិបាលជាបណ្ដោះអាសន្ន ឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ជាស្ថាពរ
- មានការបញ្ជាក់ថាមានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកប វិជ្ជាជីវៈរបស់ខ្លួន ឬ
- ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជា ឬនៅក្នុងប្រទេស ណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ ។

**មាត្រា ១៤.-**

គណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ អាចធ្វើការត្រួតពិនិត្យសម្បទាក្នុងការប្រកបវិជ្ជាជីវៈ របស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលបានគ្រប់ពេលវេលា ។

គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ ត្រូវធ្វើការពិនិត្យរាល់បណ្ដឹង ឬការរាយការណ៍ ដែលពាក់ព័ន្ធនឹងសម្បទាក្នុងការប្រកបវិជ្ជាជីវៈរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ។

បែបបទ នីតិវិធី និងលក្ខខណ្ឌដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យសម្បទាក្នុងការប្រកបវិជ្ជាជីវៈ របស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងការពិនិត្យរាល់បណ្ដឹង ឬការរាយការណ៍ខាងលើ ត្រូវកំណត់ ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៥
## ទណ្ឌកម្មខាងវិន័យ និងបណ្ដឹងតវ៉ា

**មាត្រា ១៥.-**

ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលបានប្រព្រឹត្តកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ដែលពាក់ព័ន្ធ ឬមិនមានសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈ គណៈវិជ្ជាជីវៈសុខាភិបាល ដែលពាក់ព័ន្ធអាចដាក់ទណ្ឌកម្មខាងវិន័យដូចខាងក្រោម ៖

- ធ្វើការព្រមាន
- ធ្វើការកត់ទុកក្នុងឯកសារផ្ទាល់ខ្លួន
- កំណត់លក្ខខណ្ឌផ្សេងៗចំពោះការប្រកបវិជ្ជាជីវៈសុខាភិបាលក្នុងរយៈពេលកំណត់ណាមួយ ឬជាស្ថាពរ
- ផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្ដោះអាសន្ន
- ដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាស្ថាពរ
- លុបឈ្មោះចេញពីបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ។

លក្ខណវិនិច្ឆ័យក្នុងការអនុវត្តទណ្ឌកម្មខាងវិន័យ ត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ១៦.-**

ចំពោះរាល់បណ្ដឹងទាក់ទងនឹងកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ភាគីពាក់ព័ន្ធ មានសិទ្ធិប្ដឹងជាមុនទៅគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

នីតិវិធីលើបណ្ដឹងពាក់ព័ន្ធនឹងកំហុសឆ្គងវិជ្ជាជីវៈសុខាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៧.-**

រាល់ការវិនិច្ឆ័យ និងនីតិវិធីរបស់តុលាការ ឬស្ថាប័នមានសមត្ថកិច្ចផ្សេងៗពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ចាំបាច់ត្រូវមានការចូលរួមពីគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ១៨.-**

គណៈវិជ្ជាជីវៈសុខាភិបាល អាចផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលបណ្ដោះអាសន្នជាបន្ទាន់ ក្នុងករណីដែលមានហេតុផលសមស្របសង្ស័យថា អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលណាម្នាក់

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះរាជវាំង

បានប្រព្រឹត្តកំហុសធ្ងន់វិជ្ជាជីវៈសុខាភិបាល ដែលនាំឲ្យប៉ះពាល់ដល់ជីវិតមនុស្ស ហើយដែលអាចបន្តបង្កគ្រោះថ្នាក់ដល់អ្នកផ្សេងទៀត ។

**មាត្រា ១៩.-**

គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗដែលពាក់ព័ន្ធ អាចផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន ក្នុងករណីណាមួយដូចខាងក្រោម ៖

- មានបញ្ហាសុខភាពផ្លូវកាយ ឬផ្លូវចិត្តដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈសុខាភិបាល
- នៅតែប្រព្រឹត្តកំហុសធ្ងន់វិជ្ជាជីវៈសុខាភិបាលដែលគណៈវិជ្ជាជីវៈធ្លាប់ព្រមានរួចហើយ ឬប្រព្រឹត្តខុសនឹងលក្ខខណ្ឌតម្រូវផ្សេងៗ
- ក្នុងករណីផ្សេងទៀតដែលគណៈវិជ្ជាជីវៈសុខាភិបាល រកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជាជីវៈសុខាភិបាល ។

បុគ្គលដែលត្រូវបានគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗសម្រេចផ្អាកមិនឲ្យប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន អាចស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលឡើងវិញ ដោយអនុលោមទៅតាមលក្ខខណ្ឌ និងនីតិវិធីដែលត្រូវកំណត់ដោយគណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ ។

**មាត្រា ២០.-**

គណៈវិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធត្រូវលុបឈ្មោះចេញពីបញ្ជីគណៈវិជ្ជាជីវៈសុខាភិបាល និងដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងឡាយណាដែលត្រូវបានតុលាការសម្រេចជាស្ថាពរថាមានទោសពីបទឧក្រិដ្ឋ ឬត្រូវបានតុលាការហាមឃាត់មិនឲ្យប្រកបវិជ្ជាជីវៈសុខាភិបាលជាអចិន្ត្រៃយ៍ ។

**មាត្រា ២១.-**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចអំពីទណ្ឌកម្មខាងវិន័យ ដែលធ្វើឡើងដោយគណៈ-វិជ្ជាជីវៈសុខាភិបាលដែលពាក់ព័ន្ធ មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ ក្រោយពីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចនោះ ។

**មាត្រា ២២.-**

ការទទួលរងទណ្ឌកម្មខាងវិន័យ មិនអាចធ្វើឲ្យអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលប្រព្រឹត្តខុសរួចផុតពីការទទួលខុសត្រូវខាងរដ្ឋប្បវេណី ឬ/និងការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ជំពូកទី ៦
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ២៣.-**

ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្របុរាណ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២៤.-**

ការគ្រប់គ្រងអ្នកប្រកប វិជ្ជាជីវៈសុខាភិបាលផ្សេងទៀតដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈរបស់ខ្លួន ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ២៥.-**

ជនណាដែលបានក្លែងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ២៦.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល ចំពោះជនណាដែលមិនមែនជាអ្នក វិជ្ជាជីវៈសុខាភិបាល ហើយបានប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ២៧.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០(ដប់លាន) រៀល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធនីមួយៗបានផ្អាកមិនឲ្យប្រកបវិជ្ជាជីវៈសុខាភិបាលជាបណ្តោះអាសន្ន ហើយនៅតែប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ២៨.-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន) រៀល ចំពោះអ្នកវិជ្ជាជីវៈសុខា-ភិបាលដែលប្រកប វិជ្ជាជីវៈសុខាភិបាលដោយគ្មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ។

**មាត្រា ២៩.-**

ត្រូវពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលប្រកបវិជ្ជាជីវៈសុខាភិបាលដោយអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាលអស់សុពលភាព ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

**មាត្រា ៣០.-**

ត្រូវពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន) រៀល ចំពោះអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលដែលប្រកបវិជ្ជាជីវៈសុខាភិបាលដោយរំលោភបំពានដែនកំណត់វិជ្ជាជីវៈសុខាភិបាល ឬបំពានលើលក្ខខណ្ឌដែលបានកំណត់ចំពោះការប្រកបវិជ្ជាជីវៈសុខាភិបាល ។

ករណីដែលទទួលរងការពិន័យម្តងរួចហើយ នៅតែបន្តប្រព្រឹត្តបទល្មើសដដែលត្រូវ ផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ។

## **ជំពូកទី ៨**

## **អន្តរប្បញ្ញត្តិ**

**មាត្រា ៣១.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមានក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ក្រសួងសុខាភិបាលត្រូវបង្កើតគណៈកម្មការមួយដែលរួមមានគណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ និងនាយកដ្ឋានដែលពាក់ព័ន្ធនៃក្រសួងសុខាភិបាល ។ប្រធាននៃគណៈកម្មការនេះ គឺជារដ្ឋលេខាធិការនៃក្រសួងសុខាភិបាល ។

ការរៀបចំ និងលក្ខខណ្ឌប្រតិបត្តិរបស់គណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

គណៈកម្មការនេះ មានភារកិច្ចណែនាំ និងដឹកនាំដើម្បីសម្របសម្រួល ក្នុងការកសាងសមត្ថភាពរបស់គណៈវិជ្ជាជីវៈសុខាភិបាលនីមួយៗ ដើម្បីបំពេញតួនាទីនិងភារកិច្ចដូចមានចែងក្នុងច្បាប់នេះ ។

ក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំ ដំបូងនៃការអនុវត្តច្បាប់នេះ គណៈវិជ្ជាជីវៈសុខាភិបាលអាចទទួលបាននូវថវិកាប្រតិបត្តិប្រចាំឆ្នាំពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងសមត្ថភាពរបស់ខ្លួន ដើម្បីបំពេញតួនាទីនិងភារកិច្ច ដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣២.-**

រាល់អ្នកវិជ្ជាជីវៈសុខាភិបាលដែលការចុះបញ្ជិកានៅមានសុពលភាពមុនពេលច្បាប់នេះចូលជាធរមាន នៅបន្តសុពលភាពក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៣.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន អ្នកវិជ្ជាជីវៈសុខាភិបាលមានរយៈពេល ១២ (ដប់ពីរ) ខែ យ៉ាងយូរ ដើម្បីមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសុខាភិបាល ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៣៤.-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលនៅបន្តអនុវត្តរហូតមានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

# ជំពូកទី ៩
# អវសានប្បញ្ញត្តិ

**មាត្រា ៣៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.១៦១១.១០៧៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ហត្ថលេខា**
**ម៉ម ប៊ុនហេង**

លេខ:១០៦៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ុយ សុខា**